នឹងប៉ះពាល់ដល់ហឫទ័យទុរយោធន៍ដែរ ។

ភីស្មៈផ្ងំទាំងព្រួញធ្នូស្នេកស្កះពេញខ្លួនយ៉ាងព្រងើយ មានអ្នកយាមរក្សាការពារនៅជុំវិញ រង់ចាំវេលារបស់គេនឹងធ្វើដំណើរទៅកាន់បរលោកតាមយថាកម្ម ។

អាស្រ័យការបង្វឹកបង្ហាត់ចិត្តរបស់គេយ៉ាងអស្ចារ្យ លោកស្ដេចសឹកអ្នកគ្មានបាប បានបន្ថយពេលស្លាប់ឲ្យយឺតយូរហួតទៅដល់ថ្ងៃពេញបូណ៌មីខាងមុខ ។ លុះដល់អភិលក្ខិតកាលនោះហើយ លោកស្ដេចសឹកសម្ងំសម្ងាត់បង្អោនចិត្តដ៏ក្លាហានរបស់លោក ថ្វាយព្រះជាម្ចាស់អ្នកសាងមក ។

ខាងពួកកុរុ បានហៅប្រជុំប្រឹក្សាការសង្គ្រាមម្ដងទៀត ក្នុងការប្រជុំគ្រានេះ គេបានរើសយកលោកអាចារ្យទោណ ជាស្ដេចសឹកជំនួសភីស្មៈ ។ ពួកបាណ្ឌពបានដឹងដំណឹងនេះហើយ ក៏ភិតភ័យដោយហេតុថា ទោណជាអាចារ្យរបស់គេ គេឃើញបាបកម្មក្នុងការដែលធ្វើសង្គ្រាមតស៊ូនឹងគ្រូឯង ព្រោះរាងកាយរបស់លោកគ្រូនេះក្នុងសម័យឥណ្ឌៀបុរាណ គេរាប់អានប្រកាន់ថាជារបស់ស័ក្តិសិទ្ធិសិស្សណាប្រទូសរ៉ាយមិនបានសោះ ។



ភាគទី ១៤

## ទោណាចារ្យអ្នកនាំទ័ពថ្មីខាងកុរុ

ថ្ងៃព្រឹកឡើង តអំពីការដួលនៃភីស្មៈ ទង់ជ័យកំពូលទ័ពនៃទោណាចារ្យបានទៅប្រតិស្ឋានយ៉ាងសង្ហាក្នុងស្ឋានយុទ្ធ សម្រាប់សម្ដែងគ្រឿងសំគាល់ប្រចាំជាតិ ដែលមហាជនតែងស្គាល់រាល់គ្នាថាសុវណ្ណវេទី តាំងនៅលើស្បែកម្រឹគ, វេទីនេះប្រាប់ឲ្យដឹងបព្វជិតភេទរបស់គេព្រោះព្រហ្មណាចារ្យទាំងពួង សម័យឥណ្ឌៀបុរាណជាអារណ្យវាសិន អ្នកអាស្រ័យនៅក្នុងដែនដងព្រៃស្ងាត់ចាកពពួកមនុស្ស គ្មានអាឡោះអាល័យក្នុងផ្លូវលោកីយ៍សោះ ល្បែងលែងតែប្រដៅធម៌ និងចំណេះវិជ្ជាសម្រាប់លោកខ្លះ ដល់អន្តេវាសិកកំលោះអ្នកមានហរិឱត្តប្បៈ មកនៅចោមរោមជាសិស្ស ។

ទោណ មុនដែលបានទទួលតំណែងជាចមពល បានពោលពាក្យប្ដេជ្ញាចំពោះព្រះភក្ត្រទុរយោធន៍ថា «គេនឹងទៅយកខ្លួនយុធិស្ឋិរដាក់គ្រឿងពន្ធនា មកកាន់បន្ទាយកុរុឲ្យបាន» ។

អរជុនបានឮពាក្យប្ដេជ្ញា មុខគួរឲ្យខ្លាចនេះហើយ ក៏ទូលយុធិស្ឋិរថា «លោកអាចារ្យចាស់របស់យើង ជាមនុស្សស័ក្តិសិទ្ធិណាស់ យើងនឹងយកជីវិតគេមិនបានទេ, ក្នុងការសង្គ្រាមមើលទៅដូចជាអ្នកណាក៏ដោយ យើងអាចនឹងសម្លាប់បានទាំងអស់ ឥតរើស

មុខថាទុកអ្នកនេះសម្លាប់អ្នកនោះទេ ប៉ុន្តែសូម្បីដល់ម្ល៉ឹង យើងនឹងសម្លាប់គេក្នុងសង្គ្រាមរវាងបងប្អូននេះក៏មិនបានដែរ, ទោះបីដូច្នោះក្តីពាក្យដែលលោកអាចារ្យប្តេជ្ញានោះ ជាពាក្យប្តេជ្ញាគួរឲ្យស្ងើបណាស់, ប៉ុន្តែខ្ញុំសុំប្តេជ្ញាតនឹងពាក្យប្តេជ្ញារបស់លោកគ្រូអាចារ្យថា « ដរាបណាលោហិតរបស់ខ្ញុំមាន សូម្បីតែមួយដំណក់ក្នុងកាយរបស់ខ្ញុំ, វរកាយរបស់យុធិស្ឋិរ នឹងមិនត្រូវភយន្តរាយសូម្បីតែរោមមួយសរសៃឡើយដរាបនោះ, ទោណនឹងចូលមកជិតអង្គយុធិស្ឋិរ មិនបានជាដាច់ខាតឲ្យរលែងតែដើរជិះជាន់លើសពអរជុនចូលមក»។

មុននឹងឡើងលើរថសឹក លោកអាចារ្យទោណបានចម្រើនភាវនាមួយបទនឹករឭកដល់ទេវតា និងថ្លែងសន្ទរោវាទដាស់តឿនសេនាទាហានរបស់គេពីរបីម៉ាត់ថា «ទាហានទាំងឡាយ ! កិត្តិយសនៃការនាំទាហានដ៏ក្លាហាន ធ្លាក់មកជាភារៈលើយើង ក្នុងថ្ងៃនេះការទទួលខុសត្រូវក្នុងរាជការសង្គ្រាមធ្លាក់មកលើយើងទាំងមូល តេជះគុណបុណ្យព្រះជួយឲ្យពរជ័យ យើងមានសេចក្តីសង្ឃឹមពេញទីថាម្តងនេះ សង្គ្រាមនឹងសាបសូន្យទៅ ដោយសារថ្វីដៃជ័យជម្នះរបស់កុរុ ប៉ុន្តែគ្មានមេទ័ពឬនាយពលណា សូម្បីក្លាហានជាយជ័យដូចម្តេចក្តី ក៏មិនអាចនឹងយកជ័យជម្នះ ដោយកម្លាំងរបស់ខ្លួនតែម្នាក់ឯងបានឡើយ ត្រូវតែអាស្រ័យសេចក្តីព្រមព្រៀងអស់បណ្តាពួកពលទាហានជ្រោមជ្រែង ពេញសតិកម្លាំងពួតដៃគ្នា ជួយកំចាត់ពួកបច្ចាមិត្រ ទើបអាចនឹងយកជ័យជម្នះបាន ដោយហេតុនេះហើយអ្នកទាំងឡាយចូរដឹងថា កិត្តិយសរបស់ព្រះមហាក្សត្រិយ៍ និងស្រុកទេសរបស់អ្នកការនិរាសភ័យនៃគ្រួសាររបស់អ្នក រមែងអាស្រ័យកម្លាំងកាយ និងកម្លាំងសតិបញ្ញារបស់អ្នករាល់គ្នា ជាការផ្ទុកផ្តាក់លើអ្នករាល់គ្នា មិនជាការស្ថិតនៅលើឯកជនទេ សូមឲ្យទាហានទាំងឡាយ កត់សំគាល់រឿងនេះទុកក្នុងចិត្តរបស់ខ្លួនចុះ នឹងសូមឲ្យធ្វើមុខការនាទីរបស់ខ្លួនយ៉ាងកូនប្រុសមែន ៗ មិនត្រូវទៅគិតដល់ផលក្នុងទីបំផុតទេ» ។



នៅថ្ងៃដំបូងដែលទោណាចារ្យបានទទួលតំណែងជាអ្នកបញ្ជាការទ័ពហើយ, អភិមន្យុ បុត្រអរជុន បានបញ្ចេញថ្វីដៃយ៉ាងឯកប្លែកជាងគេក្នុងការចម្បាំងសម្តែងសេចក្តីក្លាហាន ឲ្យឃើញច្បាស់ប្រាកដដល់ភ្នែកអ្នកផង ម្តងហើយម្តងទៀត បង្ហាញខ្លួនជាអ្នកចម្បាំងយ៉ាងឯកក្នុងជំនាន់ក្រោយ ដែលទើបនឹងទ្រើសធំឡើងប្រុងនឹងបានជាអ្នកធំទៅខាងមុខ ។ ការប្រយុទ្ធដណ្តើមជ័យគ្នាក្នុងថ្ងៃនេះ អភិមន្យុចូលច្បាំងនឹងកុរុរាជាមួយអង្គទ្រង់នាមថាបៅរព អភិមន្យុចាប់ទាញកន្ត្រាក់បៅរពទម្លាក់អំពីរាជរថ គ្រវាត់ដួលជ្រហឹតជ្រហាម ។

ជ័យទ្រថ ក្សត្រិយ៍សិន្ធុ កាលបានឃើញព្រះបាទបៅរពធ្លាក់នៅក្នុងភយន្តរាយ ក៏ម្នីម្នាចូលទៅជួយដោយរួសរាន់ បានរះក្រប៉ីគ្នាតនឹងអភិមន្យុ ឆាត់ហើយឆាត់ទៀត ។ អ្នកប្រយុទ្ធគ្នាទាំងពីរប្រាណមិនអាចនឹងកាប់ចាក់គ្នាត្រង់ណាបាន ដោយហេតុស្នៀតញឹកជិតស្មើ

គ្នា ។ បន្តិច ជ័យទ្រថលុតជង្គង់ចុះ ហើយចាក់សំដៅដើមទ្រូងអភិមន្យុ ប៉ុន្តែអភិមន្យុកាត់ទាន់ ក្រប៊ីទង្គិចគ្នាឮតែឆាត់ ៗ ក្រប៊ីរបស់ជ័យទ្រថបាក់ពាក់កណ្តាល ជ័យទ្រថស្ទុះរត់ឡើងលើរថសឹកបរចេញទៅអំពីស្នាមយុទ្ធ ទុកឲ្យកុរុរាជាមួយអង្គ និងព្រះបាទសល្យៈរាជាក្រុងមាទ្រៈ ចូលតយុទ្ធនឹងអភិមន្យុ ។

ក្បិណនោះ ទាហានបាណ្ឌពមួយកងលើកចូលមកជួយអភិមន្យុ ។ ភីមកាន់ដំបងមួយយ៉ាងធំ ខាងចុងមានបន្លាដូចជាបន្លាផ្លែទុរេនគ្រវីគ្រវាត់ចូលទៅរះគ្នាតតួនឹងសល្យៈទាំងពីរអង្គស្ទាត់ក្នុងក្បួនប្រើដំបងដូចគ្នា ឮតែសូរដែលផ្លាស់គ្នាវាយម្តងម្នាក់ ឮសូរហាក់ដូចសឹង្ហតោប្រខាំគ្នា ទាំងពីរអង្គឈរចំអើតជើងជ្រែងគ្រញែងកំញើញចាំកាត់ការពារកម្លាំងអាវុធ ដែលអ្នកម្ខាងវាយមកឲ្យស្រាលចុះ ដូចយ៉ាងខ្យល់បក់មកត្រូវកាយ ។ ការតស៊ូគ្នារឹតតែខ្លាំងឡើង ។ ទោះបីដល់ម្លេះក្តី អ្នកចម្បាំងទាំងពីរមិនព្រមថយចេញមួយជំហានឡើយចេះតែស៊ូទ្រាំវាត់វាយគ្នាឮសូរទឹង ៗ ទម្រាំតែខាងណាមួយដួលទៅក្នុងទីបំផុតត្រូវដួលផ្កាប់មុខទាំងពីរនាក់ ប៉ុន្តែភីមក្រោកឡើងបានមុនលើកដំបងឡើងប្រុងនឹងសំពងឲ្យស្លាប់តែម្តង ស្រាប់តែឃើញសល្យៈមានលោហិតហូរប្រាលសន្លប់បាត់ស្មារតី ក៏អនុញ្ញាតឲ្យមនុស្សសែងទៅរកកងព្យាបាលរោគ ដើម្បីចាត់ការរក្សារបួសតទៅ ។

ក្នុងភាគម្ខាងនៃស្នាមយុទ្ធនោះ ទោណាចារ្យកំពុងតែធ្វើការ



ប្រយុទ្ធនឹងបច្ចាមិត្រ លុះក្រឡេកមើលទៅឃើញយុធិស្ឋិរនៅតែមួយអង្គឯងគ្មានអ្នកណាការពាររក្សាអង្គ ក៏បររថតម្រង់ស្លឹតចូលទៅប្រុងនឹងធ្វើឲ្យបានដូចពាក្យប្តេជ្ញាទុករួចហើយថា «នឹងចាប់ឃុំនាំខ្លួនយុធិស្ឋិរយកទៅកាន់បន្ទាយកុរុឲ្យបាន» ។ ទាហានពួកបាណ្ឌពឃើញទោណាចារ្យបររថសឹកសំដៅស្លុងទៅ ក៏ស្រែកត ៗ គ្នាលាន់ទ្រហឹងពេញស្នាមយុទ្ធ ដើម្បីឲ្យជួយគ្នាប្រុងប្រយ័ត្ន ។ អរជុនដឹងថាព្រះរាជារបស់ខ្លួនធ្លាក់ទៅក្នុងទីមានភ័យហើយ ក៏ស្ទុះម្នីម្នាទៅជួយដោយរូសរាន់ បរសិន្ធពលឿនស្លៅសំដៅទៅរកយុធិស្ឋិរ បន្តិចអរជុនដែងមុខបាន ចោលមេទ័ពកុរុនៅទីខាងក្រោយ ទៅដល់ជិតអង្គយុធិស្ឋិរមុនទោណ ខំការពារមិនឲ្យទោណចូលទៅយាយីបាន ។

ក្នុងភាគដទៃនៃស្នាមយុទ្ធ មានអ្នកប្រយុទ្ធគ្នាដោយអន្លើ ៗ មិនសូវប្លែកពីថ្ងៃមុន ៗ ប៉ុន្មានទេ ក្រប៊ីនិងក្រប៊ីប៉ះទង្គិចគ្នាឮសូរតែញ៉ាំង ៗ ផ្ទួនបាក់ជាកំណាត់ ៗ សេះសឹកដួលដេកប្រកាច់លើផែនពសុធា រថសឹកបាក់ប្រែក កងរបើករបូតខ្ចាត់ខ្ចាយ ដំរីសឹកស្រែករ៉ូមរ៉ាមលើកប្រមោយត្រកងកន្ទុយបោលឆ្លេឆ្លាពាសពេញទីយុទ្ធភូមិ ប៉ុន្តែរឿងអស់នេះមិនមែនមានតែក្នុងថ្ងៃនេះទេ ពីថ្ងៃមុន ៗ ក៏មានយ៉ាងហ្នឹងដែរ ទើបមិនទើងពណ៌នាឲ្យល្អិតល្អន់សព្វគ្រប់ទេ ។ ការកាប់សម្លាប់គ្នានោះ ជារឿងធម្មតារបស់សង្គ្រាម ។ ការរត់ និងការដេញ, ការបែកទ័ព និងការប្រមូលផ្តុំពលចូលជាកងឡើងវិញ សម្លេងស្រែក

ថាមានជ័យ, សម្លេងថ្ងូររបស់អ្នកត្រូវរបួស, សម្លេងស្រែកថាប្រឹងឡើងៗ, សម្លេងពន្យុះគ្នាឲ្យចូលវាយកាប់ចាក់ទាំងអម្បាលនេះជាការមានរាល់ថ្ងៃ ដែលអ្នកបុរាណគតិសូម្បីជាអ្នកល្អិត ក៏មិនចង់ពណ៌នាឲ្យពិស្តារដែរ ។ លំដាប់នោះ វេលារាត្រីក៏ចរចូលមកដល់ត្រៃខ្លីបន្លឺស័ព្ទសញ្ញាឲ្យឈប់ច្បាំងមួយលើកទៀត ។

ព្រឹកឡើងជាថ្ងៃទី ១២ ទោណខំប្រឹងព្យាយាមធ្វើការនឹងចាប់ខ្លួនយុធិស្ឋិរឲ្យបានតាមពាក្យប្ដេជ្ញារបស់ខ្លួន គេនាំកងទាហានទាំងមូលចូលទៅដោយប៉ុនប៉ងតែម្យ៉ាង គឺនឹងចាប់យកយុធិស្ឋិរឲ្យបាន ។ ព្រួញធ្នូទាំងអស់បាញ់តម្រង់តែទៅលើអង្គយុធិស្ឋិរមួយ ដោយបំណងយ៉ាងធំនឹងកាច់យុធិស្ឋិរឲ្យបាក់ ហើយចាប់យកខ្លួនទៅបន្ទាយឲ្យបាន ។ ឧបាយកលដើម្បីចាប់យកយុធិស្ឋិរឲ្យបានងាយ គេជន្លឲ្យអរជុនឃ្លាតចេញអំពីយុធិស្ឋិរ ដោយឲ្យសុសរម័នទៅរងាវអួតច្បាំងតតួនឹងអរជុន, អរជុនក៏ទទួលច្បាំង ប៉ុន្តែភ្នែករំពៃមើលមកតែឯយុធិស្ឋិរ ព្រោះគេបានយល់កលល្បិច ដ៏ជ្រាលជ្រៅរបស់ការល្បងច្បាំងនឹងពាក្យប្ដេជ្ញារបស់ទោណនៅចាំជាប់ជានិច្ច បានប្រយុទ្ធគ្នានឹងសុសរម័ន ហើយត្រឡប់មករវាំងរក្សាយុធិស្ឋិរវិញ ។

នៅគ្រាដែលទោណលើកទ័ពតម្រង់ទៅប្រុងនឹងបង្ក្រាបយុធិស្ឋិរនោះ កងទ័ពធំក្សុរមិនបាននៅទំនេរទេ ក្សត្រិយ៍ក្សុរជាច្រើនអង្គបានចាត់ការបំបែកញែកគ្នាចូលវាយកងទ័ពបាណ្ឌពជាច្រើនផ្លូវ



បានជាធ្វើដូច្នោះ ដើម្បីនឹងវាយឲ្យបែកខ្ចាត់ខ្ចាយ ហើយចាប់យកយុធិស្ឋិរឲ្យបានដោយងាយ ។ ទុរយោធន៍ចូលវាយភីម ប៉ុន្តែទើបចូលច្បាំងបានមួយស្របក់ ក៏ត្រូវអាវុធ ត្រូវថយចេញអំពីទីស្នាមយុទ្ធ ។ អរជុនសង្កេតឃើញក្សុររួមកម្លាំងដ៏ខ្លាំងព្រួតគ្នាវាយដ៏ហូរមកប៊ីដូចជារលកទឹក ទើបគេបោលសម្រុកចូលវាយកាត់ពាក់កណ្ដាលទាហានថែវមុខ, ទាហានថែវមុខបែកទៅម្ខាងមួយថែវ ៗ ខ្ចាត់ខ្ចាយវាយជាពួកតូចៗរួមគ្នាជាកងទ័ពវិញមិនបាន ខ្លះទៅលិចខ្លះទៅកើត នេះជាថ្វីដៃយ៉ាងឯក ជាស្នាដៃមានគ្រូ ធ្វើឲ្យការរុករុលមកនៃកងទ័ពក្សុរយឺតយូរដំណើរ ធ្វើការមិនបានសម្រេចផលដូចកម្លាំង ។ កណ៌ឃើញដូច្នោះ ចិត្តរបស់គេដែលប៉ុនប៉ងតែនឹងឫស្យាព្យាបាទពេញពោរមិនអាចនឹងទប់ទល់ឲ្យស្ងប់រម្ងាប់បាន ក៏ស្ទុះចូលទៅវាយអរជុន ឥតគិតជីវិតជារស់ ឬស្លាប់ គិតតែខំយកជ័យជម្នះឲ្យបាន ឬក៏លះបង់ជីវិតជារាជពលីសម្រាប់ផែនដីប៉ុណ្ណោះ បានតដៃគ្នាជាយូរ ឮសូរស័ព្ទសន្ធឹកគឹកកង ប៉ុន្តែកណ៌ក្ដី អរជុនក្ដី គ្មានអ្នកណាបានជ័យអំពីអ្នកណាឡើយ ព្រោះអ្នកទាំងពីរប្រាណ មានកម្លាំង និងចំណេះវិជ្ជាប្រដំប្រសងគ្នា អ្នកទាំងពីរមានសេចក្ដីពេញចិត្តនឹងខ្លួនឯង ត្រង់ការដែលផ្លាស់គ្នាវាយ ផ្លាស់គ្នាទទួលរង ឥតចាញ់ប្រៀបគ្នាត្រង់ណា រហូតដល់ព្រលប់ ទើបលើកលែងប្រយុទ្ធគ្នារៀងខ្លួន ។

## ភាគទី ១៥

# មរណភាពនៃអភិមន្យុ

ថ្ងៃទី ១៣ នៃយុទ្ធវារៈវៀងរះមក ទោណមានចិត្តសប្បាយរីករាយក្រៃពេក កម្លាំងរបស់គេក៏នៅមានពេញបរិបូណ៌ កម្លាំងវេហ៍ពលសោត ក៏នៅមិនទាន់រលស់អស់ គេចាត់កងទាហានក្នុងថ្ងៃនេះជារូបសរសៃមងពីងពាង ដើម្បីធ្វើឲ្យក្រាស់ក្រួនធ្ងនការសីកវាយមកនឹងមិនធ្លុះធ្លាយចូលទៅរួច វៀរលែងតែចូលស្លាប់ ឬត្រូវគេចាប់ខ្លួន ក្បួនទ័ពច្រើនស្រទាប់ច្រើនជាន់ ដូចពោលមកហើយនោះជាយុទ្ធកិច្ចជំនាន់បុរាណរបស់ឥណ្ឌៀ ប៉ុន្តែតាមធម្មតា ឧបាយកលទាំងនេះច្រើនតែយកមកប្រើការនៅវេលាដែលឃើញថាទាល់ច្រក អស់ផ្លូវនឹងកែខៃ ហើយដើម្បីនឹងបញ្ឆោតឲ្យអរជុនផុងខ្លួនចូលទៅក្នុងទីដែលគេធ្វើកលទុកនោះ ទើបគេចោលសំដីទៅដល់អរជុនដូចកាលថ្ងៃមុន ។ អរជុនត្រិះរិះយល់ឧបាយកលនោះ ដែលមានសេចក្ដីដូចគ្នា នឹងសំដីឧបាយកលរបស់ពីងពាងអញ្ជើញរុយថា «អញ្ជើញចូលមកក្នុងបន្ទប់ទទួលភ្ញៀវរបស់ខ្ញុំចុះ» ។ អរជុនទទួលពាក្យបបួលច្បាំង ប៉ុន្តែមិនចោលនាទីរបស់ខ្លួន ទើបប្រើអភិមន្យុជាបុត្រឲ្យទៅតស៊ូជំនួសខ្លួន ។ អ្នកចម្បាំងកំលោះត្រេកអរពន់ប្រមាណ ដែលបានទទួលនាទីធ្វើការជំនួសបិតាដូច្នោះ ក៏រួសរាន់ឡើងជិះរថសីកបរ



គគ្រឹកគគ្រេងទៅទិសសមរភូមិ ហាក់ដូចជានឹងទៅបោសកងទ័ពកុរុឲ្យរលីងអស់ទៅ ដោយការរុករានតែម្ដង ។ ដើម្បីនឹងរាំងរាមិនឲ្យអភិមន្យុរុករានចូលទៅរួច ទុរយោធន៍ក៏ចូលមករាំងរាដោយកម្លាំងដ៏មហិមា ប៉ុន្តែកាលប៉ះទង្គិចគ្នាមួយក្រួសទៅ អភិមន្យុបានផ្ញើរបួសមួយអន្លើទុកនៅកាយទុរយោធន៍ និងប្រហារទាហានរក្សាអង្គទុរ-យោធន៍ស្លាប់រាល ។ អ្នកដែលចូលទៅផ្ចាញ់អភិមន្យុម្នាក់ទៀត គឺសល្យរាជាក្រុងមាទ្រៈ ។ ព្រះរាជានេះក៏ដែរ អភិមន្យុបានកាត់កម្លាំងដោយព្រួញធ្នូពីរបី ដែលបាញ់ចេញទៅមិនខុសទីដៅ ហើយក៏រុករានទន្ទ្រានចូលទៅទៀត ។

លំដាប់នោះ ទុឫាសាសនៈចេញមករាំងរាទទឹងមុខ ដើម្បីមិនឲ្យរុកចូលទៅរួច ។ អភិមន្យុឃើញ ក៏ញញឹមហើយនិយាយឡកឡឺយឲ្យថា «ទ្រង់នេះឬដែលសមគំនិតនឹងសកុនិ អូសយកអាណាចក្ររបស់យុធិស្ឋិរ ដោយអសត្យមុខគួរឲ្យខ្ពើម ? ទ្រង់នេះឬដែលចិកសិរព្រះនាងទ្រៅបទី និងប្រមាថមើលងាយក្នុងទីប្រជុំជន ? ទ្រង់ហៅភីមថា «កញ្ជះក្នុងផ្ទះទ្រង់ឬ? ទ្រង់ប្រមាថអរជុន បិតាខ្ញុំឬ ? ល្អហើយទ្រង់ជាសត្រូវជាទីគាប់ចិត្តខ្ញុំក្រៃពេក ខ្ញុំជាកូនបំណុលនៃពាក្យប្ដេជ្ញារបស់ទ្រង់ដែលគុំកួននឹងរំលាងឲ្យរលីងអំពីប្រឹថពី» និយាយដូច្នេះអ្នកចម្បាំងកំលោះក៏ចូលប្រហារទុឫាសាសនៈ ដោយកូនសរត្រូវដួលដេកលើផ្ទៃព្រះធរណី ប៉ុន្តែក្សត្រិយ៍កុរុជាច្រើន រត់ទៅជួយរួចអំពី

មរណភ័យដោយថ្វីដៃអភិមន្យុ នាំគ្នាគ្រាហ៍សែងចេញទៅអំពីស្នាមយុទ្ធ លោហិតប្រោលសន្លប់បាត់ស្មារតី ។

លំដាប់នោះ ក្សត្រិយ៍កុរុមួយអង្គទៀត ប្រឹងស្រូតរូតមកស្កាត់ស្ទាក់វាយអភិមន្យុ ប៉ុន្តែអភិមន្យុគាស់ខ្នាតបើុងទៅបាត់ដូចគេបក់រុយមួយក៏ប្រហែលគ្នា ហើយរុកចូលប្រឡូកពេញស្នាមយុទ្ធ ដេញពួកកុរុខ្ចាត់ខ្ចាយគ្មានអ្នកណាទើត ឬទល់មុខតដៃបាន ។

ក្សិណនោះ ជ័យទ្រថ ព្រះរាជាក្រុងសិន្ធូ រួបរួមកម្លាំងគ្នានឹងក្សត្រិយ៍សឹកឯទៀត ៦ អង្គចូលវាយអភិមន្យុ ។ ក្សត្រិយ៍ទាំង ៧ អង្គព្រួតគ្នាវាយអភិមន្យុជុំវិញ កូនសរប្រសាចចេញមកអំពីគ្រប់ទិសដោយឥតមេត្តាករុណា អភិមន្យុគ្មានតក់ស្លុតរន្ធត់ស្មារតីបន្តិចសោះបានធ្វើការតស៊ូនឹងសត្រូវគ្នាច្រើន កើនហួសកម្លាំងខ្លួនជាច្រើនម៉ោងក្នុងទីបំផុត ទង់រូបមយូរារបស់គេត្រូវព្រួញដាច់ធ្លាក់ដល់ដី ត្រូវរថបាក់ខ្ទេចខ្ទី ត្រូវសេះស្លាប់ នាយសារថីត្រូវគេចាប់ខ្លួនបានយកទៅទោះបីដូច្នោះ អភិមន្យុក៏ឥតព្រួចព្រឺ បានវេខ្លួនជុំវិញទទួលសត្រូវទាំង ៧ ផ្លូវ ដែលព្រួតគ្នាចូលវាយ រាងកាយពេញទៅដោយរបួសស្លាកស្នាមកញ្ឆេតកញ្ឆតអស់ទាំងសព៌ាង្គ លោហិតជាបខ្លួន មុខមាត់នឹងគ្រឿងតែងកាយ តាំងពីករហូតដល់ជង្គង់ ប្រឡាក់ដៃនឹងឈាមក្រោះក្រាំង ទោះបីដូច្នោះវីរបុរសកំលោះតូចចេះតែខំតស៊ូជរាបទៅយូរបន្តិចកើតមានអាការវិលមុខ អស់កម្លាំងប្រឹងទៅទៀតមិនរួច ក៏



ទន់ជង្គង់ចុះ ព្រោះលោហិតធ្លាក់ច្រើនណាស់ ដឹងខ្លួនថាជីវិតកំពុងស្ទុះចេញពីរាងកាយ ក្នុងទីបំផុតក៏មិនអាចនឹងទប់ទល់បានតទៅទៀត ក៏ដួលចុះអស់សតិ អស់ខ្យល់ដង្ហើមចេញចូល គេដួលដូចដំរីភ្លុកដួលក្នុងព្រៃដោយថ្វីដៃព្រានព្រៃកំណាច ប្រហារចោលក្នុងអារណ្យប្រទេស រលត់ដូចភ្លើងព្រៃរលត់ លិចទៅដូចព្រះអាទិត្យលិចបិទបាំងសិនេរុបពិត ងងឹតដូចព្រះច័ន្ទក្នុងយាមរនោច ។

វេលានោះ ព្រះអាទិត្យលិចផុតរាសី ទើបគេលើកការសង្គ្រាមក្នុងថ្ងៃនេះរង់ចាំថ្ងៃថ្មីទៅទៀត ។ គ្រានោះ ព្រះចន្ទ្រ និងដួងតារាករភ្លឺងរះត្រចះឡើងក្នុងនភាល័យប្រទេស ចែងចាំងរស្មីស្រទន់មកត្រូវសពអភិមន្យុដែលដួលដេកកណ្តាលទីយុទ្ធភូមិ ។ មុខគួរឲ្យសោកស្តាយ អ្នកចម្បាំងមានថ្វីដៃថ្មីនេះពន់ពេកណាស់ ។

អរជុននៅវេលាដែលអភិមន្យុទទួលមរណកាលនោះ នៅឃ្លាតឆ្ងាញអំពីគ្នា កំពុងតែប្រយុទ្ធក្នុងភាគម្ខាងនៃស្នាមយុទ្ធ លុះដល់ពេលលើកទ័ពត្រឡប់ចូលទៅក្នុងបន្ទាយវិញ ស្រាប់តែបានឃើញហេតុភេទដ៏អាក្រក់តាមផ្លូវជាច្រើនប្រការ ទើបសន្ទនានឹងនាយសារថីដោយសម្លេងដ៏ស្អាស្អក ព្រោះមានចិត្តស្លុតរន្ធត់ថា «នៃក្រឹស្នៈ ! ហេតុម្តេចបានជាមានហេតុភេទអាក្រក់ មកប៉ះពាល់ដល់ចក្ខុខ្ញុំក្នុងពេលព្រលប់ថ្ងៃនេះ ? ហេតុម្តេចបានជាចិត្តខ្ញុំតក់ស្លុតមុខគួរឲ្យអស្ចារ្យយ៉ាងនេះ ? ហេតុម្តេចបានជាស្វាត់ច្រៀបពេញទាំង

ស្នាមយុទ្ធ ?» លុះចូលទៅជិតបន្ទាយក៏ប្រស្រ័យនឹងក្រីស្ណៈទៀតថា «ហេតុម្តេចបន្ទាយយុធិស្ធិរ ស្ងាត់ឈឹងម្លោះក្នុងយប់នេះ ? ហេតុម្តេចបានជាអភិមន្យុ កូនតូចរបស់ខ្ញុំ មិនឃើញចេញមកទទួលខ្ញុំ ?» ។

អរជុនសន្សឹម ៗ ឈានជើងចូលទៅក្នុងបន្ទាយយុធិស្ធិរក្នុងចិត្តរេរាស្ទាក់ស្ទើរ ដោយមានសេចក្តីសន្ទិះសង្កាជាខ្លាំង ។

កាលយុធិស្ធិរ ក្រឡេកឃើញអរជុនចូលទៅ ក៏ថ្លែងរឿងអភិមន្យុដែលតដៃជាមួយរាជសត្រូវគ្នាច្រើន ត្រូវអាវុធស្លាប់កណ្តាលរណរង្គ ។

អរជុនស្រែកចេញបានតែមួយម៉ាត់ថា «អាក្មេងក្លា» ប៉ុណ្ណោះក៏ដល់នូវវិសញ្ញីភាព ដួលក្រាបផ្ទាល់ផែនដីបាត់ស្មារតីមួយស្របក់ធំ លុះបើកភ្នែកឡើងនឹកឃើញរឿងនោះ ក៏ក្រេវក្រោធញ័រទាំងខ្លួនទូលយុធិស្ធិរ ថា «ទ្រង់ថា ជ័យទ្រថព្រួតគ្នាចូលប្រយុទ្ធកាច់កិនបុត្រទូលបង្គំតែម្នាក់ឯងឬ ? ការដែលគេធ្វើដូច្នោះស្មើដូចចោរ ៧ នាក់ ព្រួតគ្នាសម្លាប់កូនក្មេងម្នាក់ រកអ្នកណាជួយគ្មាន, គួរសមហើយឬ ក្សត្រិយ៍ប្រព្រឹត្តបន្ទាបខ្លួនចុះកាន់ហិនទោស ដោយឥតអៀនខ្មាសយ៉ាងនេះ ទម្លាយច្បាប់នៃការរក្សាកិត្តិមស័ក្តិ ជាមន្ទិលសៅហ្មងខូចកេរ្តិ៍ឈ្មោះរបស់ក្សត្រិយ៍ដូច្នេះឬ ? សមឲ្យសេចក្តីក្រោធរបស់បិតាសម្លាប់វាចោលក្នុងលោកនេះ និងសូមឲ្យពាក្យផ្តាសានៃបិតា អ្នកមានបុត្រព្រាត់ប្រាសទៅហើយ តាមវាទៅក្នុងលោកឯមុខ, ឥឡូវនេះ យុធិស្ធិរ



អ្នកទ្រង់ស៊ីល ចូរស្តាប់ពាក្យប្តេជ្ញារបស់ខ្ញុំថា «សុំកុំឲ្យខ្ញុំបាននូវសេចក្តីសុខនៃស្ថានសួគ៌ឡើយ ថាបើខ្ញុំសម្លាប់ជ័យទ្រថមិនបានក្នុងថ្ងៃស្អែកនេះទេ, សុំកុំឲ្យវិញ្ញាណរបស់ខ្ញុំទៅកាន់និរយភូមិ និងទទួលទោសទណ្ឌកម្មជួសសត្វបាបដែលមានទោសធ្ងន់ ៗ នោះ បើមុនព្រះអាទិត្យអស្តង្គតក្នុងថ្ងៃស្អែកនេះ ខ្ញុំសម្លាប់ជ័យទ្រថមិនបានទេ»។

យប់នេះ មានសេចក្តីសោយសោកបរិទេវនាការក្នុងបន្ទាយបាណ្ឌពពេញមួយរាត្រី លុះដល់ថ្ងៃព្រឹកឡើង អរជុនដណ្តើមយកស័ង្ខសឹកមកផ្លុំខ្លួនឯង សម្លេងរន្ថើនរន្ទាន់ជាអាណត្តិសញ្ញាសម្រាប់ពាក្យប្តេជ្ញាដ៏ពន្លឹក ដែលគេនឹងធ្វើឲ្យបានសម្រេច នូវវេលាមុនព្រះអាទិត្យអស្តង្គតថ្ងៃនេះ ។

ពួកកោរពបានដឹងពាក្យសច្ចាប្រណិធានរបស់អរជុន ហើយបានឮសម្លេងស័ង្ខរបស់អរជុនទៀត ក៏ត្រៀមការតស៊ូយ៉ាងសាហាវក្នុងថ្ងៃនោះ អ្នកខ្លះដែលសម្លាប់អភិមន្យុក៏ព្រួញខ្លួន ។ ឯជ័យទ្រថមិនហ៊ានចេញទៅទទឹងមុខអរជុន រកផ្លូវគេចវេះទៅនៅក្រោយកងទ័ព ហើយបានស្តេចចូលទៅឯបាវំទុរយោធន៍ មុនអរុណរះទូលថា «ពាក្យសច្ចាប្រណិធានរបស់អរជុនថា នឹងយកជីវិតខ្ញុំឲ្យបានក្នុងថ្ងៃនេះ ចោះចំពោះតែឈ្មោះខ្ញុំម្នាក់ ជាការកែកំហឹងសងសឹករបស់គេតាំងពីដើមមកគេមិនដែលពោលពាក្យមុតមាំសម្បើមដូច្នេះ ព្រោះពូជពង្សវង្សត្រកូលរបស់គេ ត្រូវពួកកោរពពិឃាតបង់រាល់ ៗ ថ្ងៃ បាន

ជាគេឈឺចាប់ខ្លាំងណាស់ក្នុងថ្ងៃនេះ, អរជុនជាមនុស្សប្រាកដប្រជា ហើយជាសត្រូវដ៏របឹងរបស់យើង ហេតុនេះ ពាក្យប្ដេជ្ញារបស់គេមិនមែនជាពាក្យផ្ដេសផ្ដាសទេ យើងនឹងឡកឡឺយ ឬធ្វេសប្រហែសមិនបានសោះឡើយ ខ្ញុំគិតក្រែងថា សេចក្ដីស្លាប់របស់ខ្ញុំនឹងមកដល់ក្នុងគ្រានេះ»។

ទុរយោធន៍ «កុំព្រួយ ! សម្រាប់ជាតិអ្នកចម្បាំង ដែលនឹងមកប្រារព្ធខ្លាចស្លាប់យ៉ាងនេះមិនគួរសោះឡើយ, រាល់ខណៈដង្ហើមចេញចូលរបស់ទាហាននោះ ជាការប្រឡែងលេងនឹងសេចក្ដីស្លាប់ ខ្ញុំចង់និយាយថា ជំនួសថ្ងៃនេះជាវារៈទីបំផុតនៃជីវិតទ្រង់នោះ វាក្លាយទៅជាមរណៈនៃ អរជុនទៅវិញ»។

ជ័យទ្រថ «ភ័យរបស់ខ្ញុំជិតចូលមកដល់ហើយណ៎ា»។

ទុរយោធន៍ «មិនអីទេ ! កងទ័ពខ្ញុំទាំងអស់ ខ្ញុំបានផ្ដាំឲ្យចាំការពាររក្សាទ្រង់ដោយប្រយ័ត្នប្រយែងក្នុងថ្ងៃនេះ យ៉ាងអស់ពីចិត្ត ហេតុនោះទ្រង់កុំខ្លាចអ្វីឡើយ»។

ក្បិណនោះ ក្រៃខ្លីបន្លឺស្វរស័ព្ទឡើងដើម្បីឲ្យត្រៀមចម្បាំង អរជុនលោតឡើងលើរថសឹកដោយរួសរាន់ ហើយផ្ដាំក្រឹស្ណៈថា «ចូរបរសេះសម្បុរផ្ទៃមេឃរបស់ខ្ញុំឲ្យលឿនតាមដែលអាចបរបាន ព្រោះថ្ងៃនេះ ការងាររបស់ខ្ញុំជាការងាររួសរាន់គួរឲ្យស្ញែងណាស់ ខ្ញុំត្រូវធ្វើការឲ្យបានសម្រេចក្នុងថ្ងៃនេះតាមសំដីរបស់ខ្ញុំ ប្រសិនខ្ញុំធ្វើការនោះ



មិនបានសម្រេចក្នុងថ្ងៃនេះទេ ខ្ញុំត្រូវតែលះបង់ជីវិតរបស់ខ្ញុំមិនខានដែរ»។

រថសឹកអរជុន លាន់ឮគគ្រឹកស្ទើរកក្រើកទាំងស្នាមយុទ្ធ រត់ពីចុងស្នាមយុទ្ធម្ខាងទៅដល់ចុងស្នាមយុទ្ធម្ខាងទៀត ។ មានអ្នកលេងពួកកុរុមកទទឹងផ្លូវមុខរថសឹកអរជុនខ្លះដែរ អ្នកដំបូងគឺទុរមរស័ណ ប៉ុន្តែ អរជុនវាយរត់ប្រទ្បោតគោតតួងទៅដោយងាយ ហើយក៏បររថទៅទៀត ។

លំដាប់នោះ ទុហាសាសនៈចូលវាយអរជុន ដោយខ្លោងដំរីសឹកមួយខ្លោងធំ, ដំរីសឹកគ្រាន់តែឮស្វររថសឹកអរជុន ក៏ដាលបោលប្រសាចទៅអរជុនបររថបង្ខំឃ្មីខ្មាតទៅរកជ័យទ្រថទៀត ។ តពីនោះ ទោណាចារ្យចេញមកស្កាត់មុខអរជុន ហើយបបួលច្បាំងតតួ ប៉ុន្តែ អរជុនសុំខ្លួនដោយសុភាពថា ចូរឲ្យអភ័យដល់កូនសិស្សចុះ ថ្ងៃនេះកូនសិស្សមិនទទួលច្បាំងនឹងលោកអាចារ្យទេ ដ្បិតមានអំពល់រវល់តាមរកវាយអ្នកដែលសម្លាប់អភិមន្យុបុត្រខ្ញុំ ឲ្យបានសម្រេចតាមពាក្យប្ដេជ្ញាដ៏ធំ ដែលខ្ញុំបានតាំងប្រណិធានទុករួចមកហើយនោះ ។ រថសឹកអរជុនក៏លឿនគគ្រឹក ក្បែរខាងទោណទៅតាមថែវទាហានដែលដំកង់ជាវង់ឥន្ទធនូ វាយកំចាត់ពលដែលនៅទទឹងមុខឲ្យវិនាសចេញទៅ ។

ពេញមួយថ្ងៃនោះ ឮតែស្វររថសឹកអរជុន គ្រឹកទៅ គ្រឹកមក ខ្ទរ

ខ្មាំងទូទៅទាំងស្នាមយុទ្ធ ខំស្វែងរកតែជ័យទ្រថ មិនទាន់ជួបប្រទះសោះ ។ ក្រឹស្ណៈឃើញសេះនឿយហត់ណាស់ ក៏បញ្ឈប់ដោះសេះចេញពីរថ ឲ្យឈប់សម្រាកស៊ីស្មៅ នៅក្រោមម្លប់ឈើមួយដើម បានមួយស្របក់ក៏យកសេះមកទឹមវិញ ហើយបររថជ្រៀតជ្រែកទៅក្នុងកណ្ដាលកងទ័ពកុរុ សង្វាតរកតែជ័យទ្រថ ប៉ុន្តែជ័យទ្រថមិនហ៊ានអើតមុខចេញមក ឲ្យប្រាកដដល់ចក្ខុអរជុនសោះ ។ មានក្សត្រិយ៍កុរុឯទៀតជាច្រើនអង្គ មកតទល់នឹងអរជុនដែរ ប៉ុន្តែអង្គខ្លះត្រូវអរជុនប្រហារខ្ទេចទៅ, អង្គខ្លះមកល ៗ ក៏គេចបាត់ទៅ ថ្ងៃសោតក៏កាន់តែទន់ទាបណាស់ទៅហើយ ការដែលស្វែងរកជ័យទ្រថមិនជួបនោះ អរជុនរកកលនឹងខូចចិត្តទៅហើយ ប៉ុន្តែគ្រោះជា គ្រានោះ ទទួលអរជុនចោលភ្នែកក្រឡេកមើលទៅចុងស្នាមយុទ្ធម្ខាងឯណោះស្រាប់តែបានឃើញជ័យទ្រថគង់លើរថសឹក ឫកពាក្រអឺតក្រអោង រឹងប៉ឹងមានទាហានមួយកងពលធំហែហមអមអង្គចាំការពារ ។ អរជុនរកក្រឡេកមើលទៅព្រះអាទិត្យក៏ជិតអស្តង្គតណាស់ទៅហើយ ទោះជាយ៉ាងណាក៏មិនត្រូវបណ្ដោយឲ្យពេលវេលាកន្លងទៅទទេដែរ ស្ងួម្បីឃើញដូច្នោះហើយ ក៏មិនមែនជានឹងចូលទៅវាយបានដោយងាយ ៗ ដ្បិតកណ៌ដែលជាតួអង្គរក្សយ៉ាងសំខាន់ នៅចាំរក្សាអង្គជ័យទ្រថនោះ, ឃើញអរជុនបររថតម្រង់ស្ទៅចូលទៅរកជ័យទ្រថ ក៏ស្ទុះស្ទារចេញមកទទួលតដៃនឹងអរជុន ដោយបំណងនឹងរារាំងបង្អង់ឲ្យវេលា



ផុតរលត់ទៅ ព្រោះវេលានៅសល់តែពីរ ឬបីនាទីទៀតប៉ុណ្ណោះទេព្រះអាទិត្យនឹងលិចបាត់ហើយ បើពេលនោះ អរជុនធ្វើការមិនបានសម្រេចទេ គេក៏ត្រូវលះបង់ជីវិតរបស់ខ្លួនដែរ នេះជាគំនិតរបស់កណ៌ដែលគិតទុកតែក្នុងចិត្តថា «បានឱកាសល្អហើយ ចំពោះការព្យាបាទនឹងអរិចិត្តគ្នារហូតដល់អាយុក្ខ័យ វេលានេះអញនឹងកាច់អរជុនឲ្យដួលទាំងជំហរ កុំឲ្យមានផ្លូវក្រោកឡើងរួច» ។

ក្រឹស្ណៈឃើញថាអរជុនធ្លាក់ទៅក្នុងទីចង្អៀតចង្អល់ប្រផុតប្រផើយមិនដឹងជានឹងបរាជ័យ ឬមានជ័យដូច្នោះ ព្រះហឫទ័យទ្រង់ជាទុក្ខយ៉ាងខ្លាំង ។ ក្នុងគ្រាមួយរំពេចនោះ ហាក់បីដូចជាមានទេវតាដ៏មានឫទ្ធានុភាពមកជួយភ្លាម ៗ មេឃមីរងងឹតខ្មួលខ្មៅគ្រប់ទិសបិទបាំងមណ្ឌលព្រះទិនករងងឹតសូន្យសុង ទាល់តែកណ៌គិតថាដល់វារៈទីបំផុតនៃការសញ្ញារបស់អរជុនហើយ ទើបគេលើកលែងធុរៈក្នុងការច្បាំងទៀត ដើរចេញអំពីស្នាមយុទ្ធព្រងើយ ដោយសប្បាយចិត្ត នេះជាលាភរបស់អរជុន ។ ក្សិណនោះ ពពកខ្មួលខ្មៅនោះ ក៏រសាត់ដាច់បាត់អស់ទៅ ព្រះអាទិត្យលេចពន្លឺភ្លឺផ្លេកឡើងមួយរំពេចក្នុងវេលាប្រមាណជាមួយខណៈ អរជុនប្រកាន់យកឱកាសនោះបានស្ទុះលុកលុយចូលទៅពិឃាតជ័យទ្រថស្លាប់ភ្លាមនឹងកន្លែង ពាក្យប្ដេជ្ញាដ៏ធំរបស់គេក៏បានសម្រេចដល់ទីបំផុតដោយប្រការដូច្នេះ ។

កាលជ័យទ្រថត្រូវអរជុនពិឃាតស្លាប់ដូច្នោះហើយ ពួកខាង

កុរុក៏ឈឺចាប់ជាយ៉ាងធ្ងន់ ត្រូវគិតធ្វើការសងសឹកវិញឲ្យគ្រាតែបាន, ក្នុងគ្រាជាដំបូងដៃ កើតការច្បាំងគ្នាទាំងរាត្រី នៅយប់នោះ គប់ភ្លើងភ្លឺព្រោងព្រាយពេញទាំងទីចម្បាំង, អុជបំភ្លឺមើលគ្នាទៅវិញទៅមក ដើម្បីនឹងធ្វើការប្រឡូងយកជ័យឲ្យទាន់ក្ដៅចិត្ត, ក្របីភ្លឺព្រាត ៗ ក្នុងវេលាត្រូវពន្លឺគប់ភ្លើងចាំងមក មុខគួរឲ្យស្រៀវខ្លួនណាស់ ចាប់ច្បាំងតាំងពីថ្ងៃរហូតដល់យប់ទៀតជាច្រើនម៉ោង មិនដាច់ស្រេចជាខាងណាមានជ័យខាងណាបរាជ័យឡើយ ។ កងទ័ពទាំងពីរខាងបានច្បាំងគ្នាដោយទោសៈឥតស្រាកស្រាន្ត ក្នុងទីបំផុត អស់កម្លាំងរៀងខ្លួន ក៏ព្រមព្រៀងគ្នាឈប់សម្រាកមួយគ្រាសិន ។

ជាគ្រោះអាក្រក់ ថ្ងៃនេះធ្វើឲ្យទុរយោធន៍ព្រួយហឫទ័យយ៉ាងខ្លាំងម្ដងទៀត បានស្ដេចចូលទៅរកទោណាចារ្យ ហើយត្រាស់ថា «ខ្ញុំព្រួយចិត្តធំណាស់ ដ្បិតអីថៃវទាហានកុរុ ចេះតែរលស់ស្ដើងតិចទៅជាលំដាប់ ចម្បាំងរបស់យើង ចេះតែថយដៃចុះរាល់លើក ចុះហេតុអ្វីកាលយើងបានអ្នកចម្បាំងយ៉ាងឯក រកមនុស្សប្រៀបផ្ទឹមគ្មាន ដូចយ៉ាងលោកអាចារ្យនេះ មកធ្វើជាមេទ័ពរបស់យើងហើយ ម្ដេចឡើយក៏នៅតែទើសទាក់ មិនបានសម្រេចផលទៀត ? តើនៅមានគន្លាក់កន្លៀតត្រង់ណាទៀត ? ឬមួយព្រោះតែចិត្តរបស់លោកទន់ដូចយ៉ាងភីស្មៈបណ្ដាលឲ្យដៃរបស់លោកទន់ខ្សោយទៅផង ? ឬក៏ព្រោះតែពួកក្សត្រិយ៍បាណ្ឌពជាកូនសិស្សរបស់លោក ? ប្រសិនបើជាពិត



ដូច្នេះតែយ៉ាងណាមួយ ក្នុងនាមនៃយុត្តិធមិសម្រាប់ជាតិ ម្ដេចក៏លោកមិនប្រគល់តំណែងរបស់លោកឲ្យទៅកណ៌វិញទៅ ? » ។

សេចក្ដីរំជួលនឹកដល់កណ៌ បានកើតមានឡើងដល់ទុរយោធន៍រាល់ ៗ គ្រា ដែលកងទ័ពរបស់ទ្រង់ត្រូវគេវាយច្រានថយទៅ ឬត្រូវបរាជ័យ ទ្រង់តិះដៀលដល់ភីស្មៈ មិនតិចជាងបីដងដោយសំគាល់ថា ភីស្មៈយកចិត្តទុកដាក់ខាងពួកបាណ្ឌពជាង ហើយរាល់តែលើកទ្រង់គិតនឹងអបលោកកណ៌ឲ្យធ្វើជាមេទ័ព ក្នុងគ្រានេះក៏ទៀតដែរ កាលទុរយោធន៍បានឃើញអរជុនរក្សាពាក្យប្ដេជ្ញាទុកបាន ធ្វើការទាល់តែបានសម្រេចដូចបំណង ហើយមិនឲ្យមានអន្តរាយដោយសេចក្ដីព្យាបាទរបស់សត្រូវទៀតនោះ ព្រះហឫទ័យទ្រង់ ក៏ស្រងូតស្រងាត់ខ្លាំងណាស់ ប៉ុន្តែទ្រង់នឹកសង្ឃឹមថា កណ៌នឹងយកជ័យជម្នះមកវិញបាន ដូចទឹកហូរចុះទៅសមុទ្រធំ អាចធ្វើឲ្យត្រឡប់ហូរច្រាសឡើងមកវិញបាន ។ ទោណក្រាបទូលដូចភីស្មៈធ្លាប់ក្រាបទូលមកហើយថា «ទុរយោធន៍ បើកងទ័ពរបស់ទ្រង់បែកខ្ញែកទៅហើយ វាមិនមែនដទៃឆ្ងាយទេ គឺផលនៃអកុសលរបស់ទ្រង់ហ្នឹងឯងកុំទៅបន្ទោសអ្នកស្ទាត់ក្នុងការចម្បាំង ដែលមានសក់ស្កូវសព្រោងពេញក្បាលដូចយ៉ាងខ្លួនទូលបង្គំថាប្រកបដោយអសត្យ មានប្រទូស្តចិត្តនោះឡើយ ព្រះអង្គនៅជាយុវកុមារណាស់ មិនត្រូវមើលរំលងចាស់ទេ ត្រូវតែទ្រង់ជ្រាបថា អរជុនគ្មានអ្នកប្រៀបផ្ទឹមស្មើបានទេ ក្នុងផ្លូវយុទ្ធវិជ្ជា

នឹងត្រូវទ្រង់ជ្រាបថា ទោណមិនបាច់ឲ្យទ្រង់ជាស់តឿនក្នុងកិច្ចការជាមុខងាររបស់ទោណទេ ដើម្បីនឹងឲ្យទ្រង់ជ្រាបសេចក្ដីពិតក្នុងរឿងនេះ ទូលបង្គំសុំតាំងសច្ចាប្រណិធានក្នុងទីនេះថា «ថ្ងៃនេះ អរជុននឹងស្លាប់ដោយស្នាដៃទូលបង្គំ ឬបើមិនដូច្នោះទេ ក៏ទូលបង្គំនឹងស្លាប់ខ្លួនឯងវិញ» ។

លុះព្រះទិនករភ្លឺស្វាងពសុធា គេចាប់ធ្វើការសង្គ្រាមយ៉ាងក្ដៅដៃជាងមុន ១ ។ ឃដោត្កចៈជាអ្នកមានថ្វីដៃ បានជ័យជម្នះក្នុងថ្ងៃនេះ ឈ្មោះនេះជារក្សសៈ បុត្រភីម បានធ្វើមរណកម្ម និងភេរវកម្ម ដល់ពួកទាហានកុរុដោយទោសៈនៃរក្សសៈ, ខ្លួនគេថ្ងៃនេះមើលទៅហាក់ដូចជាមានឫទ្ធិខុសពីធម្មតា គេធ្វើឲ្យសាច់ស្វិតគង់ធន់កាប់មិនមុតមុខគួរអស្ចារ្យ គេមិនញញើតនឹងរឿងស្លាប់ នឹងការធ្លាក់ខ្លួនទៅជាឈ្លើយនៃសត្រូវដូចមនុស្សធម្មតា ។ ការដែលនឹងកម្រាបគេបាននោះ មានតែអានុភាពនៃទេវតាម្យ៉ាងប៉ុណ្ណោះ ។ គ្រានោះ កណ៌ជាទាហានឯកយ៉ាងសំខាន់ម្នាក់ដែរ មានកូនសរដ៏អស្ចារ្យ ដែលព្រះឥន្ទ្រប្រទានមកតែមួយគត់ ពួកគេតឿនឲ្យយកកូនសរនោះចេញសម្លាប់ឃដោត្កចៈ តួសំខាន់នេះចេញ កណ៌ក៏ព្រមតាមសេចក្ដីយល់ឃើញរបស់គេរាល់គ្នា ប៉ុន្តែឯគោលបំណងរបស់កណ៌ គិតសំចៃកូនសរនេះទុកនឹងសម្លាប់អរជុន ដែលអ្នកខ្លាំងពូកែជាងខ្លួនគេ ប៉ុន្តែឃដោត្កចៈមកសម្ដែងឫទ្ធិយុកយាក់មុខគេយ៉ាងនេះ នាំឲ្យគេទ្រាំទប់ទល់ពុំ



បាន ក៏ថ្លែងសរនោះផ្ដាច់ផ្ដិលជីវិតឃដោត្កចៈឲ្យក្ស័យទៅ កាលឃដោត្កចៈត្រូវទេពាវុធក្ស័យទៅហើយលំដាប់នោះ ការកោលាហលក្នុងស្នាមយុទ្ធ ក៏ស្ងាត់ប្រៀបដូចគេលត់ ប៉ុន្តែការស្ងប់ស្ងាត់នេះដូចយ៉ាងវេលាស្ងប់ស្ងាត់មុនផ្គរលាន់លើមេឃ ព្រោះគ្រាន់តែស្ងាត់មួយស្របក់ប៉ុណ្ណោះ ក្រោយពីនោះ មិនយូរប៉ុន្មាន ក៏មានការរើធ្វើសឹកនឹងគ្នាជាថ្មីទៀត ឮស្វរសន្ធឹកសន្ធាប់ជាងមុនទ្វេជាពីរភាគ ។ លុះស្រេចការប្រហារឃដោត្កចៈ ហើយកណ៌ក៏តម្រង់ត្រង់ស្លុងចូលទៅរកសត្រូវចាស់របស់គេ គឺព្រះរាជាទ្រុបទ ក្រុងបញ្ចាល និងព្រះរាជាវិរាជ ក្សត្រិយ៍ទាំងពីរអង្គនេះត្រូវកណ៌ប្រហារខ្ទេចទៅ នៅវេលាជាមួយគ្នា សេចក្ដីសច្ចាប្រណិធានរបស់កណ៌ក៏បានសម្រេចយ៉ាងរីករាយសប្បាយចិត្ត ។ ការបង្គាប់បញ្ជារបស់ទោណបាននាំមកនូវជ័យជម្នះ ឬបើយ៉ាងហោចណាស់ ក៏ត្រឹមសងសឹកគ្នាវិញបាន មិនឲ្យចាញ់ប្រៀបសត្រូវ ។